ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០១៨

**សេចក្តីផ្តើម** :

នៅក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និង មមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្ត មុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០៣លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន ០១លើក ដើម្បីពិនិត្យ និងសម្រេចលើ របាយការណ៍អនុវត្តចំណូល ចំណាយថវិកា ព្រឹទ្ធសភា ឆ្នាំ២០១៧ និងគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០១៨ និងពិនិត្យ និងឲ្យយោបល់លើសេចក្តី ព្រាងច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា ៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មក្រមព្រហ្មទណ្ឌ សេចក្តីព្រាងច្បាប់ ស្តីពី វិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការ អចិន្ត្រៃយ៍ ប្រជុំពេញអង្គ និងប្រជុំអន្តរគណៈកម្មការ ព្រឹទ្ធសភា<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវា ភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗ សរុបចំនួន០៩លើក មានអ្នកចូលរួមចំនួន៦០៧នាក់<br>- ថតចម្លងឯកសារបានចំនួន១,២៦៨ច្បាប់ អស់ក្រដាសចំនួន២៥,៤៣០សន្លឹក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និង មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន២៩លើក |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម<br>- បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងច្បាប់ចំនួន០៣ច្បាប់។ | - បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន១៣២នាក់ ស្មើនឹង០៧លើក<br>- បានទទួលសេចក្ដីព្រាងច្បាប់ចំនួន០៤ច្បាប់ពីរដ្ឋសភា និងរាជរដ្ឋាភិបាល ហើយបានចាត់ចែងតាមនីតិវិធី<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស ដីការអម និងលិខិតផ្សេងៗ ចំនួន២៩៧ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតីលើសេចក្ដីព្រាងច្បាប់ចំនួន០៤ច្បាប់<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៥លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន០៤លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្ដីជូនដំណឹង សេចក្ដីប្រកាសព័ត៌មានចំនួន១២លើក ។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន និងជួបជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តកោះកុង និងខេត្តព្រះសីហនុ ។ | - បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្តក្រុង និងរាជធានីភ្នំពេញចំនួន៤០នាក់ ស្មើនឹង០៥លើក |

**៣.មុខងារតំណាង** :

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - *សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖*<br>+ *អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធអគារមន្ទីរពេទ្យ* ***សម្តេចឪ សម្តេចម៉ែ*** *ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់* ***ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង* ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅក្នុងបរិវេណមន្ទីរពេទ្យបង្អែក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ*<br>+ *អញ្ជើញជូនព្រះរាជដំណើរ* ***ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង* ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ព្រះអង្គស្តេចយាងចេញពីមាតុប្រទេសទៅកាន់សាធារណរដ្ឋប្រជាមានិតចិន*<br>+ *អញ្ជើញជាអធិបតីបើកកម្មវិធីប្រកួតវាយកូនហ្គោលពានរង្វាន់* ***សម្តេចវិបុលសេនាភក្តី សាយ ឈុំ*** *នៅទីលានវាយកូនហ្គោលដីហ្ក្រេនភ្នំពេញ រាជធានីភ្នំពេញ*<br>+ *អញ្ជើញនាំយកបច្ច័យ ទេយ្យវត្ថុ អង្ករ គ្រឿងឧបភោគ បរិភោគ និងចង្ហាន់ទៅវេរ* | - *រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្សេងៗសរុបចំនួន២៩៦លើក*<br>- *បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការចុះជួបសំណេះសំណាល ចែកអំណោយ ការចុះតាមដានឈ្វេងយល់អំពីវឌ្ឍនភាពក្រោយការរៀបចំវេទិកា និងការឈ្វេងយល់ពីការប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកម្មវិធីផ្សេងៗ នៅខេត្តត្បូងឃ្មុំ កំពង់ចាម ក្រចេះ សៀមរាប ព្រៃវែង ស្វាយរៀង ព្រះសីហនុ កោះកុង ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី*<br>- *បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤៧នាក់ ស្មើនឹង៤៧ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន១៦រូប ស្មើនឹង១៦ច្បាប់*<br>- *ថតចម្លងឯកសារបានចំនួន១,៨៦៦ច្បាប់ អស់ក្រដាសចំនួន១០,៥០៥សន្លឹក*<br>- *បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន២២៥នាក់ ស្មើនឹង៣៤លើក* |

| | |
|---|---|
| ប្រគេន **សម្តេចព្រះវនរ័តកិត្តិបណ្ឌិត ណយ ច្រឹក** ព្រះសង្ឃនាយករងទី៣ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្ត ព្រមទាំងព្រះសង្ឃ ព្រះសមណសិស្ស និស្សិត សរុបចំនួន៩១អង្គ គង់នៅវត្តច័ន្ទបុរីវង្ស រាជធានីភ្នំពេញ<br>+ អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីបញ្ចុះសព និងពិធីបុណ្យខួបគម្រប់៧ថ្ងៃ សពលោកជំទាវ **ហ៊ុន វណ្ណវឌ្ឍនា** អ្នកឧកញ៉ា **ដួង ឈីវ** និងឯកឧត្តម **ឯក វីរៈដេដ្ឋ** នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការរោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុន **ជីប ម៉ុង អ៊ិនស៊ី ស៊ីមេន ខបភើរេសិន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកំពត<br>+ អញ្ជើញជាអធិបតី និងដឹកនាំក្រុមសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល និងសួរសុខទុក្ខអាជ្ញាធរ សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋចំនួន២,២៧៦នាក់ នៅខេត្តកំពត ខេត្តកែប និងខេត្តកណ្តាល<br>+ អញ្ជើញចូលរួមប្រជុំពិនិត្យរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅ | - បានទទួលលិខិតចូលចំនួន៩៤៧ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៣៩ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៥០លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៥នាក់ ស្មើនឹង០៣លើក<br>- បានធ្វើលិខិតជូនពរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ក្នុងឱកាសចម្រើនជន្មាយុ៧៣ ឈានចូល៧៤ឆ្នាំ<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៣លើក<br>- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៩នាក់<br>- បានធ្វើតារាងស្ថិតិទិន្នន័យ និងចងក្រងសៀវភៅបញ្ជីឈ្មោះក្រុមប្រឹក្សាឃុំ សង្កាត់ និងបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បន្ទាប់ពីបែងចែកអាសនៈដែលទំនេរស្របតាមមាត្រា២០ និងមាត្រា២១ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់<br>- បានផ្តល់អត្តបទ និងរូបថតចំនួន៨០២សន្លឹក ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៦៨នាក់ |

| | |
|---|---|
| ការងារឆ្នាំ២០១៨ របស់សមាគមមិត្តភាពកម្ពុជា-ចិន<br>+ អញ្ជើញពិនិត្យមើលការជួសជុលសាលប្រជុំពេញអង្គព្រឹទ្ធសភា និងបានចុះពិនិត្យមើលការសាងសង់ព្រះវិហារ និងប្រគេនបច្ច័យចំនួន៤,០០០ដុល្លារ សម្រាប់ក្រាលឥដ្ឋការ៉ូឡា ជុំវិញព្រះវិហារ នៅវត្តប្រាំបីមុំ ខេត្តតាកែវ<br>- បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងដំណើរការនីតិកម្មរបស់ព្រឹទ្ធសភាជូនដល់សាស្ត្រាចារ្យ និស្សិត មកពីវិទ្យាស្ថានជាតិសង្គមកិច្ច និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន ៩៥នាក់<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០៥ករណី បញ្ជូនពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី ធ្វើការឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន ០៥ករណី ព្រមទាំងបានទទួលពាក្យបណ្តឹងជូនជ្រាបចំនួន១៣ករណី និងជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន០១ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញទូទាំងប្រទេសចំនួន២៣១លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យ | ធ្វើប័ណ្ណសមាជិកបណ្ណាល័យចំនួន០៦នាក់ ខ្ចីសៀវភៅចំនួន៣២ក្បាល និងសងវិញចំនួន ២២ក្បាល<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាចំនួន០២លើក របស់សាស្ត្រាចារ្យ និងនិស្សិត មកពីវិទ្យាស្ថានជាតិសង្គមកិច្ច សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន៩៥នាក់<br>- បានទទួលឯកសារ សៀវភៅ ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងព្រឹត្តិបត្រ ទស្សនាវដ្តី និងរាជកិច្ច ពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២១២១ក្បាល កាសែត និងព្រះរាជក្រមចំនួន១៦៩ច្បាប់<br>- បានរៀបចំទស្សនាវដ្តីប្រចាំខែមករា ឆ្នាំ២០១៨<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតវីដេអូសម្រាប់បង្ហោះលើ Alert News ចំនួន១៨២ប្រធានបទ<br>- បានថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន៦៥លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥០លើក<br>- បានផលិត និងផ្សព្វផ្សាយវីដេអូស្តីពី សមិទ្ធផលព្រឹទ្ធសភានីតិកាលទី៣ និង៣នីតិកាល ចំនួន ០៥ខ្សែ ។ |

| | |
|---|---|
| ស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់សម្ភោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤៩លើក។ | |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| វេទនាសម្ព័ន្ធនយោបាយ | វេទនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រធានព្រឹទ្ធសភា បានជួបសម្តែងការគួរសម និងសវនាការជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពថ្មីនៃសាធារណរដ្ឋឥណ្ឌា ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពថ្មីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រធានក្រុមតំណាងរដ្ឋសភាទីក្រុងហូជីមិញ និងគណៈប្រតិភូក្រុមប្រឹក្សានៃសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន<br>- សមាជិកព្រឹទ្ធសភា បានអនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតសិង្ហបុរី ឯកអគ្គរដ្ឋទូតឡាវ និងអគ្គកុងស៊ុលឡាវ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងសវនាការចំនួន០៤លើក ព្រមទាំងពិធីប្រគល់ និងទទួលកុំព្យូទ័រលើតុ កុំព្យូទ័រយួរដៃ ម៉ាស៊ីនព្រីនធ័រ និងម៉ាស៊ីនហ្វូតូកូពី ដែលជាជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម<br>- បានរៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាភេសជ្ជៈ និងផ្គត់ផ្គង់សម្ភារអនាម័យក្នុងពិធីផ្សេងៗចំនួន១១លើក ស្មើនឹង១២៥នាក់<br>- បានថតចម្លងឯកសារចំនួន៣៦ច្បាប់ អស់ក្រដាសចំនួន២២៨សន្លឹក |

| | |
|---|---|
| | - បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៨០នាក់ ស្មើនឹង៥០លើក<br>- បានធ្វើកំណត់បង្ហាញ លិខិតអញ្ជើញ និងលិខិតឆ្លើយតបទៅក្រសួង និងបណ្តាអង្គទូតនានាចំនួន០៩លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៣នាក់ ស្មើនឹង០៦ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន២៨លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង០៨លើក<br>- អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយនាយកផ្នែកកសាងសមត្ថភាពនៃវិទ្យាស្ថានសភាកម្ពុជា(PIC) សាស្ត្រាចារ្យខាងការទូតបារាំង និងសមាជិកព្រឹទ្ធសភាបារាំង<br>- បានទំនាក់ទំនងជាមួយស្ថានទូតបារាំង ព្រឹទ្ធសភាបារាំង សភាសហព័ន្ធវ៉ាល់ឡូនី-ព្រុចសែល សមាគមបេសកកម្មសិក្សាអាស៊ី និងក្រសួងស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៦៤ច្បាប់ ។<br>**+ការងារគ្រប់គ្រងបុគ្គលិកៈ**<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៣៣ច្បាប់<br>- ប្រជុំស្តីពី រចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់អគ្គាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំពិនិត្យនិងកែសម្រួលក្រមសីលធម៌មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រកាសដាក់ជាធរមានបទបញ្ជាផ្ទៃក្នុងនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ដែលបានធ្វើវិសោធនកម្ម<br>- រៀបចំរាយតម្លៃតម្លើងថ្នាក់បៀវត្ស និងគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- កំពុងចាត់ចែងការបកប្រែជាភាសាបារាំងស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០១៨-២០២៤) ក្នុងបរិបទព្រឹទ្ធសភា នីតិកាលទី៤ (២០១៨-២០២៤) ។<br>**+ការងារបណ្តុះបណ្តាលធនធានមនុស្ស :**<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេស សរុបចំនួន០៤វគ្គ មានសិក្ខាកាម |

| | |
|---|---|
| | ចូលរួមចំនួន២១នាក់<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) ដើម្បីរៀបចំកម្មវិធីសិក្ខាសាលាតំបន់ និងត្រៀមកម្មវិធីបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់សភាអាស៊ាន។<br>**+ចាត់ចែងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**<br>- ប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងគោល-ការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៨<br>- ប្រជុំវាយតម្លៃឯកសារដេញថ្លៃស្តីពី ការផ្គត់ផ្គង់ការបោះពុម្ព សម្ភារការិយាល័យ និងសម្ភារអនាម័យ<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ២២សំណើ និងផ្គត់ផ្គង់សម្ភារអនាម័យ សម្ភារការិយាល័យ និងភេសជ្ជៈចំនួន៦៤សំណើ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន១៦លើក |

| | |
|---|---|
| | មានអ្នកចូលរួមចំនួន៧០៥នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន៣៤២លើក<br>- បានថតចម្លងឯកសារចំនួន១០,៥០០ច្បាប់ និងចងក្រងសៀវភៅចំនួន០៣ក្បាល អស់ក្រដាសចំនួន២១,១១៣សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១២៥នាក់ ស្មើនឹង៧៥លើក។<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:**<br>- រៀបចំគម្រោងស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤<br>- កសាងអគារថ្មី០១ខ្នងសម្រាប់ជាការិយាល័យធ្វើការបណ្តោះអាសន្ន<br>- បញ្ចប់ការកែលម្អសួនច្បារជុំវិញសាលប្រជុំពេញអង្គ ការជួសជុលស្លាបខាងឆ្វេង និងខាងស្តាំនៃសាលប្រជុំពេញអង្គ និងការបំពាក់សម្ភារបរិក្ខារ<br>- បានជួសជុលអគារសមាជិកព្រឹទ្ធសភា (DEF) និងការបំពាក់សម្ភារបរិក្ខារ សម្រាប់នីតិកាលថ្មី<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ ផ្លូវថ្នល់ បណ្តាញទឹក លូទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដ |

| | |
|---|---|
| | សម្ភារសារពើភ័ណ្ឌ និងប្រគល់សម្ភារសរុបចំនួន ៣០០គ្រឿង<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឲ្យមានសោភ័ណភាពល្អ<br>- បានតាំងពិព័រណ៍រូបភាពនៅព្រឹទ្ធសភាចំនួន០៤លើក<br>- ចូលរួមសហការជាមួយលេខាធិការដ្ឋានអមគណៈកម្មការទាំង១០ព្រឹទ្ធសភា ដើម្បីរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ(NAS)<br>- បានសហការជាមួយក្រុមហ៊ុន KOHA ដើម្បីផ្លាស់ប្តូរប្រព័ន្ធ PMB មកKOHA ដើម្បីសម្រួលដល់ការគ្រប់គ្រងឯកសារ និងសៀវភៅនៅបណ្ណាល័យ<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន១៧គ្រឿង ។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៨៧ចំណងជើង ។<br>**+ការងារផ្សេងៗ:**<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន៤៣លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ដាក់លេខកូដ និងបញ្ជូនសៀវភៅដាក់នៅសាលអាន ព្រមទាំងជួសជុលឯកសារ |

| | |
|---|---|
| | សៀវភៅចាស់ៗសរុបចំនួន៣០៥ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម PMB E-Library បណ្ដាញ Facebook សរុបចំនួន៥,៩៨៤ក្បាល ។ |

**II.ទិសដៅការងារខែមីនា ឆ្នាំ២០១៨**

**១.ផ្នែកការងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គលើកទី១១ ព្រឹទ្ធសភា នីតិកាលទី៣ ដើម្បីបញ្ចប់នីតិកាលទី៣

-ត្រៀមបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាល៤

-ត្រៀមបោះពុម្ពអត្ថបទច្បាប់ និងសៀវភៅសំខាន់ៗរបស់ស្ថាប័ន

-បញ្ចប់ការចងក្រងក្រមសីលធម៌សម្រាប់មន្ត្រីរាជការ និងបន្តការវាយតម្លៃតម្លើងថ្នាក់បៀវត្ស និងគ្រឿងឥស្សរិយយសមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

**២.ផ្នែកការងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ ។

**៣.ផ្នែកការងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ ( ពិធីសម្ពោធសមិទ្ធផលខេត្តកណ្ដាល និងពិធីបុណ្យខេត្តកោះកុង )

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមប្រារព្ធទិវាបុណ្យអន្តរជាតិនារី ០៨ មីនា (គណៈប្រតិភូក្រសួងកិច្ចការនារី និងផ្នែកក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា )

-ត្រៀមបញ្ចុះសីមាព្រះវិហារ នៅវត្តភូមិហ្វាង ខេត្តរតនគិរី

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.ផ្នែកការងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីទទួលឯកអគ្គរដ្ឋទូតប្រទេសនានា

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ក្នុងនាមជាប្រមុខរដ្ឋស្ដីទី និងប្រធានព្រឹទ្ធសភាស្ដីទី

ជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា (ត្រៀមទទួលសារតាំងទូតអេហ្ស៊ីប ទូតតួកគី និងត្រៀមជំនួបទូតកូរ៉េ)

-ត្រៀមទទួលដំណើរទស្សនកិច្ចគណៈប្រតិភូអគ្គលេខាធិការព្រឹទ្ធសភាប៉ាគីស្ថាន(ខែមីនា ឆ្នាំ២០១៨)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-សមាជិកព្រឹទ្ធសភាចំនួន០២រូប ទៅចូលរួមសង្កេតការបោះឆ្នោតប្រធានាធិបតីនៅសហភាព-សហព័ន្ធរុស្ស៊ី បេសកកម្មសភាក្នុងក្របខ័ណ្ឌអន្តរជាតិ)

-ការចូលរួមប្រជុំ(ASGP) និងទស្សនកិច្ចការងារនៅរដ្ឋសភា ព្រឹទ្ធសភាបារាំង និងលេខាធិការដ្ឋាន (APF)

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-ត្រៀមសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា (PIC), (IPU), និង (APF)

-ត្រៀមចូលរួមវគ្គបណ្ដុះបណ្ដាលនានាដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC)

-ការអនុវត្ត (MOU)សហប្រតិបត្តិការជាមួយព្រឹទ្ធសភាឥណ្ឌា និងប៉ាគីស្ថាន ដើម្បីឈានទៅបង្កើតអគ្គនាយកដ្ឋានខាងការស្រាវជ្រាវ ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-ត្រៀមកសាងអគារ០១ខ្នង និងឃ្លាំង០១ខ្នង ព្រមទាំងបំពាក់សម្ភារបរិក្ខារថ្មី

-បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារប្រើប្រាស់រួមមាន៖ អគារការិយាល័យសមាជិកព្រឹទ្ធសភា ព្រមទាំងរៀបចំគូសគំនូសចំណតរថយន្ត និងស្លាកសញ្ញាបង្ហាញផ្លូវ (ផ្នែកខាងជើង)

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី សម្ភារបរិក្ខារអេឡិចត្រូនិច និងរថយន្ត

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្ដាប់ធ្នាប់ អនាម័យការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្ដើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្ដល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក តាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំគណៈកម្មការពិនិត្យក្រមសីលធម៌សម្រាប់មន្ត្រីរាជការ និងការកែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បញ្ចប់ការវាយតម្លៃតម្លើងថ្នាក់បៀវត្ស និងគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) និងការបំពាក់សម្ភារបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត ឆ្នាំ២០១៨

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការបូកសរុបលទ្ធផលការងារព្រឹទ្ធសភាក្នុងនីតិកាលកន្លងមក

-ការត្រៀមចាត់ចែងសម័យប្រជុំដំបូងរបស់ព្រឹទ្ធសភានីតិកាលទី៤

-ការត្រៀមរៀបចំយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (២០១៩-២០២១) គម្រោងថវិកាឆ្នាំ២០១៩

-ការត្រៀមរៀបចំថវិកាកម្មវិធីឆ្នាំ២០១៩

-បន្តការងារលទ្ធកម្ម (ប្រេងឥន្ធនៈ និងសំលៀកបំពាក់)

-ការអនុវត្តថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៨ ដោយមានជំហានធ្វើបច្ចុប្បន្នភាពប្រចាំខែ

## III.សេចក្តីសន្និដ្ឋាន

ខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានការងារមមាញឹកនៅគ្រប់ការដ្ឋាន ក្នុងបរិបទដែលការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ និងការត្រៀមសម្រាប់នីតិកាលថ្មីខាងមុខបានមកដល់ ។ ជាពិសេសអគ្គលេខាធិការដ្ឋាន បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម មុខងារតំណាង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភាបានដោយរលូន ។ ការអភិវឌ្ឍស្ថាប័នតាមរយៈការបង្កើនសមត្ថភាពស្រាវជ្រាវ និងប្រើប្រាស់

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារឲ្យបានជាអតិបរមា ព្រមទាំងសមត្ថភាពភាសាបរទេស និងជំនាញផ្សេងៗទៀត ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានបន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់ព្រឹទ្ធសភានីតិកាលថ្មីតាមរយៈវិទ្យាស្ថានសភាកម្ពុជា(PIC) និងដៃគូអភិវឌ្ឍន៍នានា ហើយកើតចេញជាលទ្ធផលថ្មីៗក្នុងការដើរតួនាទីសំខាន់កាន់តែទូលំទូលាយ ។

អគ្គលេខាធិការដ្ឋានត្រូវត្រៀមធ្វើការក្នុងនីតិកាលថ្មី (២០១៨-២០២៤) តាមរបៀបថ្មី គំនិតថ្មី ដោយពុំធ្វើតែតាមរបៀបចាស់ដដែលៗ ។ ត្រូវហ៊ានគិត ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ ។ អគ្គលេខាធិការដ្ឋានត្រូវក្តាប់ជាប់ទស្សនវិស័យរួម និងតាំងចិត្តធ្វើដំណើរទៅមុខជានិច្ច តាមក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័ន (២០១៨-២០២៤)។ សេវា និងផលិតផលគ្រប់យ៉ាង ត្រូវតែមានគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល គុណភាព និងល្បឿនលឿនជាងមុន ។ ការគោរពច្បាប់ និងវិន័យ ត្រូវក្លាយជាទម្លាប់ល្អនៃជីវិតការងារជាអចិន្ត្រៃយ៍ ។

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ